ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍
សំណុំរឿងព្រហ្មទណ្ឌ
លេខ៩៩០/០២-១១-២០១១
សាលដីកា
លេខ០៣ក្រVIយ
ចុះថ្ងៃទី០៨-០១-២០១៤

តាងនាមប្រជារាស្ត្រខ្មែរ
សាលាឧទ្ធរណ៍

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៦ក្រចុះថ្ងៃទី០៩-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ថ្ងៃទី២៤-១២-២០១៣ដែលមានសមាសភាពដូចតទៅ៖

<u>**សមាសភាពក្រុមប្រឹក្សាជំនុំជំរះ**</u>

**លោក** [redacted] **ប្រធាន**

**លោក** [redacted] **ចៅក្រមប្រឹក្សា**

**លោក** [redacted] **ចៅក្រមប្រឹក្សា**

**តំណាងមហាអយ្យការ**

**លោក** [redacted]

**ក្រឡាបញ្ជី**

**លោកស្រី ម៉េ**[redacted]

ជំនុំជំរះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌ៖

<u>**I-សំណុំរឿងព្រហ្មទណ្ឌលេខ៩៩០/០២-១១-២០១១ដែលមាន៖**</u>

**-ជនជាប់ចោទឈ្មោះ** [redacted]**សាខុច ហៅ ឈី ហៅ ជី** (**ដើមបណ្តឹងឧទ្ធរណ៍**) ភេទប្រុស អាយុ៥២ឆ្នាំ ជាតិខ្មែរ មុខរបរជាងជួសជុលម៉ូតូ កើតនៅសង្កាត់ផ្សារអំពៅ រាជធានីភ្នំពេញ ទីលំនៅសព្វថ្ងៃជាប់ក្នុងពន្ធនាគារ(PJ) រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] (ស)ម្តាយឈ្មោះ[redacted] ប្រពន្ធឈ្មោះ[redacted]មានកូន១នាក់ ។ទោសពីមុនមាន ។ចាប់ខ្លួនថ្ងៃទី១៣-១២-២០០៨។**មានមេធាវី**[redacted]**ម៉ាច**.

ត្រូវចោទពីបទ ប្រើប្រាស់គ្រឿងញៀនបណ្តាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ប្រព្រឹត្តនៅចំណុចពន្ធនាគារ(PJ)អាគារAក្នុងបន្ទប់លេខ១ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨-១០-

២០១០បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៣ថ្មី កឋាខណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**ដំណើររឿងមានដូចតទៅៈ**

កាលពីថ្ងៃទី២៨-១០-២០១០វេលាម៉ោង៨ព្រឹក សមត្ថកិច្ចបានចុះត្រួតពិនិត្យនៅក្នុងពន្ធនាគារ(PJ) ក្នុងបន្ទប់លេខ១ និង បន្ទប់លេខ៤ក្រោមការដឹកនាំរបស់ព្រះរាជអាជ្ញារង ឃើញមានថ្នាំញៀនប្រភេទម៉ាទឹកកកចំនួន៣កញ្ចប់ និង ប្រភេទហេរ៉ូអ៊ីនចំនួន៨កញ្ចប់ ដែលជារបស់ឈ្មោះយាយហាយ ជាអ្នកដាំបាយឲ្យឈ្មោះ[redacted]សារុធ ហៅ ឈី ហៅ ជី យកមកប្រគល់ឲ្យឈ្មោះ[redacted] សារុធ ដើម្បីយកមកឲ្យឈ្មោះ[redacted]ខេមម៉ាលី ហៅ ផល្លី ចែកចាយបន្តក្នុងពន្ធនាគារ(PJ) ដោយមានការមើលការខុសត្រូវពីឈ្មោះ[redacted] សៀក ដែលជាអនុរក្សពន្ធនាគារ។

**ច្បាប់ឃើញ**សាលក្រមព្រហ្មទណ្ឌលេខ៧៧ក្រ១ណ/១៩-៨-២០១១របស់សាលាដំបូងរាជធានីភ្នំពេញ សំរេចសេចក្តីដូចតទៅៈ

១-ផ្តន្ទាទោសលើឈ្មោះ[redacted]សារុធ ហៅ ឈី ហៅ ជី ភេទប្រុស អាយុ៥២ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល០៤ឆ្នាំ(បួនឆ្នាំ) ពីបទប្រើប្រាស់គ្រឿងញៀនបណ្តាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ប្រព្រឹត្តនៅចំណុចពន្ធនាគារ(PJ)អាគារAក្នុងបន្ទប់លេខ១ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨-១០-២០១០បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៣ថ្មី កឋាខណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-កែប្រែបទចោទប្រកាន់លើឈ្មោះ[redacted] សៀក ភេទប្រុស អាយុ៤៨ឆ្នាំ ពីបទ សមគំនិតក្នុងអំពើចែកចាយគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅចំណុចពន្ធនាគារ(PJ)អាគារAក្នុងបន្ទប់លេខ១ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨-១០-២០១០ តាមមាត្រា២៩ នៃក្រមព្រហ្មទណ្ឌ និង មាត្រា៣៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មកជាបទសំរួលដោយចេតនាឲ្យប្រើប្រាស់គ្រឿងញៀនខុសច្បាប់ តាមមាត្រា៣៥.២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-ផ្តន្ទាទោសលើឈ្មោះ[redacted] សៀក ភេទប្រុស អាយុ៤៨ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល០៣ឆ្នាំ(បីឆ្នាំ) តែទោសនេះអនុវត្តក្នុងពន្ធនាគារ១០ខែ ទោសនៅសល់ពីនេះត្រូវព្យួរ ពីបទសំរួលដោយចេតនាឲ្យប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅចំណុចពន្ធនាគារ(PJ)អាគារAក្នុងបន្ទប់លេខ១ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨-១០-២០១០ តាមមាត្រា៣៥.២ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង មាត្រា១០៧ និង មាត្រា១០៨នៃក្រមព្រហ្មទណ្ឌ។

៤-ឲ្យឈ្មោះ[redacted]ខេមម៉ាលី ហៅ ផល្លី ភេទស្រី អាយុ៤៥ឆ្នាំ រួចខ្លួនពីបទ ចែកចាយគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅចំណុចពន្ធនាគារ(PJ)អាគារAក្នុងបន្ទប់លេខ១ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨-១០-២០១០ តាមមាត្រា៣៥០នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៥-វត្ថុចាប់យករួមមាន៖

ក/ស្រោមសំបុត្រពណ៌លឿង បិទស្កុតជិតចំនួន១ និង មានស្នាមមេដៃ ពណ៌ក្រហមចំនួន២ ព្រមទាំងហត្ថលេខា និង ឧបករណ៍សំរាប់ជក់គ្រឿងញៀន១ចំនួន តាមកំណត់ហេតុទទួលវត្ថុតាងពីចៅក្រមស៊ើបសួរលេខ៤៨០វតចុះថ្ងៃទី០៣-១១-២០១០ ត្រូវរិបអូសបំផ្លាញចោល តាមមាត្រា៨៥នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ/ទូរស័ព្ទដៃម៉ាកណូគា ចុចពិល (ផលិតនៅប្រទេសចិន)ចំនួន១គ្រឿង ត្រូវរិបអូសទុកជាសម្បត្តិរដ្ឋ តាមមាត្រា៦២នៃក្រមព្រហ្មទណ្ឌ។

គ/ទូរស័ព្ទដៃម៉ាកណូគាN៨២ និង ណូគាN៩៧ត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ តាមមាត្រា៣៥៨នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-សាលក្រមនេះជំនុំជំរះជាសាធារណៈថ្ងៃទី១០-៨-២០១១ និង ប្រកាសជាសាធារណៈនៅថ្ងៃទី១៩-៨-២០១១ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ។ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ម្នាន់ឃើញ**ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៥-៨-២០១១របស់ឈ្មោ[redacted]សារុធ មិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៧៧ក្រ១ណ/៣០-១០-២០១០របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសេចក្តីសំរេចទាំងមូល។

បានឃើញរបាយការណ៍របស់សាលាឧទ្ធរណ៍។

បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

**<u>នាពេលសវនាការ</u>**

ចៅក្រមអានរបាយការណ៍របស់សាលាឧទ្ធរណ៍.

ជនជាប់ចោទឈ្មោ[redacted]សារុធឆ្លើយថាៈខ្លួនអាយុ៥២ឆ្នាំ ជាតិខ្មែរ មុខរបរជាងជួសជុលម៉ូតូ កើតនៅសង្កាត់ច្បារអំពៅ រាជធានីភ្នំពេញ ទីលំនៅសព្វថ្ងៃជាប់ក្នុងពន្ធនាគារ (PJ) រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted](ស)ម្តាយឈ្មោ[redacted]ប្រពន្ធឈ្មោះ[redacted] មានកូន១នាក់ ។ទោសពីមុនមាន។ចាប់ខ្លួនថ្ងៃទី១៣-១២-២០០៨។ខ្លួនប្តឹងឧទ្ធរណ៍ ព្រោះខ្លួនមិនបានលក់ដូរគ្រឿងញៀនក្នុងពន្ធនាគារទេ ខ្លួនគ្រាន់តែជក់គ្រឿងញៀនក្នុងពន្ធនាគារប៉ុណ្ណោះ។ពេលខ្លួនជាប់ក្នុងពន្ធនាគារ ខ្លួនតែងតែជក់ថ្នាំញៀននៅពេលយប់ជារៀងរាល់ថ្ងៃក្នុងបន្ទប់ ហើយថ្នាំញៀននោះឈ្មោះយាយហាយបានយកមកឲ្យដោយលាក់ក្នុងនំប៉័ង ត្រីប្រឡាក់កញ្ចប់បារី ឬផ្ទាល់ដៃនៅពេលគេមិនចាប់អារម្មណ៍។ យាយហាយយកគ្រឿងញៀនមកឲ្យខ្លួនច្រើនដង តែខ្លួនមិនដែលឲ្យលុយគាត់ទេ។នៅក្នុងគុកខ្លួនជក់គ្រឿងញៀននេះ ដើម្បីកុំឲ្យឈឺចង្កេះ ខ្លួនជក់តែម្នាក់ឯងប៉ុណ្ណោះ។វត្ថុតាងដែលប៉ូលីសរិបអូសបាននេះ គឺខ្លួនទទួលស្គាល់។សំណូមពរសុំបន្ធូរបន្ថយទោសដល់ខ្លួនឲ្យបានទាបផង ខ្លួនជាប់ក្នុងគុក៥ឆ្នាំហើយ។

តំណាងមហាអយ្យការសន្និដ្ឋានថាៈ ជនជាប់ចោទឈ្មោ[redacted]សារុធ បានឆ្លើយសារភាពថាពិតបានជក់គ្រឿងញៀនក្នុងពន្ធនាគារមែន។អង្គហេតុ និង សេចក្តីសំរេចរបស់សាលាដំបូងមានលក្ខណៈត្រឹមត្រូវហើយ សុំគំកល់សាលក្រមព្រហ្មទណ្ឌលេខ៧៧ ក្រ១ណ/១៩-៨-២០១១របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការដដែល។

មេធាវី [redacted] ម៉ាច សន្និដ្ឋានថាៈខ្លួនជាមេធាវីការពារឲ្យឈ្មោ[redacted] សារុធ។កូនក្តីខ្លួនជាប់ក្នុងពន្ធនាគារ គាត់តែងតែជក់ថ្នាំញៀននៅពេលយប់ជារៀងរាល់ថ្ងៃក្នុងបន្ទប់ ហើយថ្នាំញៀននោះឈ្មោះយាយហាយបានយកមកឲ្យ ដោយលាក់ក្នុងនំប៉័ង ត្រីប្រឡាក់កញ្ចប់បារី ឬផ្ទាល់ដៃ ។យាយហាយយកគ្រឿងញៀនមកឲ្យកូនក្តីខ្លួនច្រើនដង តែកូនក្តីខ្លួនមិនដែលឲ្យលុយគាត់ទេ។នៅក្នុងគុកកូនក្តីខ្លួនជក់គ្រឿងញៀននេះ ដើម្បីកុំឲ្យឈឺចង្កេះ កូនក្តីខ្លួនជក់តែម្នាក់ឯងប៉ុណ្ណោះ។វត្ថុតាងដែលប៉ូលីសរឹបអូសបាននេះ គឺកូនក្តីខ្លួនទទួលស្គាល់។សំណូមពរសុំបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនឲ្យបានទាបផង និង សុំស្រូបទោសបញ្ចូលគ្នា។

**II-សំណុំរឿងព្រហ្មទណ្ឌលេខ៥៣២/០១-៩-២០០៩ដែលមានៈ**

**-ជនជាប់ចោទឈ្មោះ[redacted]សារុធ ហៅ ឈី ហៅ ជី (ដើមបណ្តឹងឧទ្ធរណ៍)** ភេទប្រុស អាយុ៥២ឆ្នាំ ជាតិខ្មែរ មុខរបរជាងជួសជុលម៉ូតូ កើតនៅសង្កាត់ច្បារអំពៅ រាជធានីភ្នំពេញ ទីលំនៅសព្វថ្ងៃនៅផ្ទះលេ[redacted]ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះមិនស្គាល់ (ស)ម្តាយឈ្មោះ[redacted](ស) ប្រពន្ធឈ្មោះ[redacted]មានកូន១នាក់ ។ទោសពីមុនគ្មាន។ចាប់ខ្លួនថ្ងៃទី១៣-១២-២០០៨.

ត្រូវចោទពីបទ ជួញដូរគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅសង្កាត់ផ្សារថ្មីទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣-១២-២០០៨បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៣ថ្មី កឋាខណ្ឌទី៣ ចំណុច«គ»និង «ជ»នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**ដំណើររឿងមានដូចតទៅៈ**

កាលពីថ្ងៃទី១៣-១២-២០០៨វេលាម៉ោង១១ម៥០នាទី សមត្ថកិច្ចការិយាល័យប្រឆាំងគ្រឿងញៀនបានឃាត់ខ្លួនបុរសម្នាក់ឈ្មោះ[redacted] លីហាយ នៅចំណុចផ្លូវលេខ ១១០ កែងផ្លូវលេខ១១៧ សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដោយដកហូតបានគ្រឿងញៀន ប្រភេទមេតំហ្វេតាមីន(ទឹកកក)១កញ្ចប់ទំងន់០.៩៣ក្រាម។ផ្អែកតាមចំលើយសារភាពរបស់ឈ្មោ[redacted] លីហាយ នៅថ្ងៃដដែលនោះ សមត្ថកិច្ចចុះឆែកឆេរលំនៅដ្ឋានរបស់ឈ្មោ[redacted] សារុធ ហៅ សួនជី ដែលមានទីតាំងផ្ទះលេខ២០៧ ផ្លូវលេខ១១៨ សង្កាត់ផ្សារថ្មីទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដោយបានដកហូតគ្រឿងញៀន មេតំហ្វេតាមីនចំនួន៤៨០គ្រាប់ ហេរ៉ូអ៊ីនទំងន់៣៩.៩១ក្រាម ម្សៅសទំងន់៤៨.៥៩ក្រាម ដុំម្សៅពណ៌ប្រផេះទំងន់១៥១,៧៩ក្រាម និង គ្រាប់ថ្នាំពណ៌ទឹកក្រូចមាន

សញ្ញា០២៨ និង បន្ទះថ្នាំលេខ៥ ចំនួន០៩បន្ទះ ស្មើនឹង៩០គ្រាប់ ព្រមទាំងឃាត់ខ្លួនឈ្មោះ[redacted] សាវុធផងដែរ។

**ម្នានឃើញ**សាលក្រមព្រហ្មទណ្ឌលេខ៧២ក្រ២/០៩-៦-២០០៩របស់សាលាដំបូងរាជធានីភ្នំពេញ សំរេចសេចក្ដីដូចតទៅៈ

១-ផ្តន្ទាទោសលើឈ្មោះ[redacted] លីហាយ ហៅ ញ៉ ភេទប្រុស អាយុ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់១២ខែ គិតពីថ្ងៃឃុំខ្លួនថ្ងៃទី១៧-១២-២០០៨.

ពីបទចែកចាយគ្រឿងញៀន ប្រព្រឹត្តនៅសង្កាត់ផ្សារចាស់ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣-១២-២០០៨ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង មាត្រា៦៨ កថាខណ្ឌទី២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

២-ផ្តន្ទាទោសលើឈ្មោះ[redacted] សាវុធ ហៅ សួនជី ភេទប្រុស អាយុ៥០ឆ្នាំ ដាក់ពន្ធនាគារកំណត់១០ឆ្នាំ និង ពិន័យជាប្រាក់ចំនួន២០.០០០.០០០៛(ម្ភៃលានរៀល).

ពីបទជួញដូរគ្រឿងញៀន ប្រព្រឹត្តនៅសង្កាត់ផ្សារថ្មីទី១ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣-១២-២០០៨ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៣ថ្មី កថាខណ្ឌទី៣ ចំណុច«គ»និង «ជ» នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-វត្ថុតាងគឺៈ

ក/គ្រឿងញៀន ប្រភេទម្សៅឈ្មោះហេរ៉ូអ៊ីនទំងន់៣៩.៩១ក្រាម មានកំរិតភាពសុទ្ធ៧៤.៧ភាគរយនៃទំងន់សរុបស្មើនឹង២៩.៧៣២៩ក្រាម.

-គ្រឿងញៀន ប្រភេទម្សៅឈ្មោះកេតាមីន ទំងន់៤៨.៥៤ក្រាម មានកំរិតភាពសុទ្ធ៧៤.៧ភាគរយនៃទំងន់សរុបស្មើនឹង៣៦.២៥៩៣ក្រាម.

-គ្រឿងញៀនប្រភេទគ្រាប់ឈ្មោះមេតំហ្វេតាមីនចំនួន២០គ្រាប់ ទំងន់២.០១២ក្រាម មានកំរិតភាពសុទ្ធ១៣.៥ភាគរយ នៃទំងន់សរុប ស្មើនឹង០.២៧១៦ក្រាម.

-គ្រឿងញៀនប្រភេទគ្រាប់ឈ្មោះអិម.ដេ អិម.អា ចំនួន១២៦គ្រាប់ ទំងន់សរុបស្មើ៣៦.៩១៨ក្រាម មានកំរិតភាពសុទ្ធ២៨.៧ភាគរយ នៃទំងន់សរុបស្មើ៩.២៧៤៣ក្រាម លាយសារធាតុញៀន១មុខទៀត ឈ្មោះមេតំហ្វេតាមីន មានកំរិតភាពសុទ្ធ១.៨ភាគរយនៃទំងន់សរុបស្មើនឹង០.៣៧៥៨ក្រាម បរិមាណសារធាតុសុទ្ធ សរុបទាំង២មុខស្មើនឹង៩.៦៥៩៧ក្រាម.

-គ្រឿងញៀនប្រភេទគ្រាប់ឈ្មោះមេតំហ្វេតាមីន មានកំរិតភាពសុទ្ធ៩.២ភាគរយនៃទំងន់សរុបលាយសារធាតុញៀន១មុខទៀត ឈ្មោះកេតាមីន មានកំរិតភាពសុទ្ធ៧.៦ភាគរយនៃទំងន់ សរុបចំនួន២៥០ក្រាម ទំងន់សរុបស្មើ៦៦.១៧៥ក្រាម មានកំរិតភាពសុទ្ធមេតំហ្វេតាមីន សរុបស្មើ៦.០៨៨១ក្រាម និង កំរិតភាពសុទ្ធកេតាមីនសរុបស្មើនឹង

៥.០២៩៣ក្រាម សរុបកំរិតភាពសុទ្ធទាំង២មុខស្មើនឹង១១.១១៧៩ក្រាម.

-គ្រឿងញៀនប្រភេទគ្រាប់ឈ្មោះអិម.ដេ អិម.អា ចំនួន៨៨គ្រាប់ ទំងន់សរុប២៥.៣៤២៨ក្រាម មានភាពសុទ្ធជាមធ្យម៤៣.៧៥ភាគរយនៃទំងន់សរុបស្មើ ១១.០៨៦២ក្រាម.

-គ្រឿងញៀនប្រភេទគ្រាប់ឈ្មោះមេតាហ្វេតាមីន ចំនួន៩០គ្រាប់ ទំងន់សរុប១.៦២ក្រាម មានកំរិតភាពសុទ្ធ៣ភាគរយ នៃទំងន់សរុបស្មើនឹង០.០៨៨៦ក្រាម សរុបបរិមាណសារធាតុញៀនទាំង៨មុខ ស្មើនឹង៩៨.១៦៥៧ក្រាម.

-គ្រឿងញៀនប្រភេទក្រមម្សៅឈ្មោះមេតំហ្វេតាមីន ទំងន់០.៩៣ក្រាម មានកំរិតភាពសុទ្ធ៧៧.៦ភាគរយ នៃទំងន់សរុបស្មើនឹង០.៧២១៦ក្រាម.

-កែវសំរាប់ជក់ថ្នាំញៀន១ចំនួន ត្រូវរិបអូសបំផ្លាញចោល។

ខ/ទូរស័ព្ទដៃម៉ាកBIRDចំនួន១គ្រឿង ទូរស័ព្ទដៃម៉ាកNOKIA៦៣០០ចំនួន១គ្រឿង ប្រាក់អាមេរិកចំនួន៣០ដុល្លា និង ប្រាក់រៀល១០០៦០០រត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ។

តាមមាត្រា៨៥ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៤-សាលក្រមនេះជំនុំជំរះនៅថ្ងៃទី០៩-៦-២០០៩ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី១០-៦-២០០៩ចំពោះមុខជនជាប់ចោទ។ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**បានឃើញ**ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២២-៦-២០០៩របស់ឈ្មោ[redacted]សារុធ មិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៧២ក្រ២/០៩-៦-២០០៩របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសេចក្តីសំរេចទាំងមូល។

បានឃើញរបាយការណ៍របស់សាលាឧទ្ធរណ៍.

បានឃើញសេចក្តីសន្និដ្ឋានរបស់មហាអយ្យការ.

**__នាពេលសវនាការ__**

ចៅក្រមអានរបាយការណ៍របស់សាលាឧទ្ធរណ៍.

ជនជាប់ចោទឈ្មោ[redacted] សារុធ ឆ្លើយថា៖ខ្លួនប្តឹងឧទ្ធរណ៍ព្រោះខ្លួនមិនបានជួញដូរគ្រឿងញៀនទេ ។ថ្នាំហេរ៉ូអ៊ីនទំងន់ប្រហែល១០ជី ជាម្សៅពណ៌ស មានតំលៃប្រហែល៧០០$ជាង គឺខ្លួនបានចូលលុយគ្នាទិញ ដើម្បីចែកគ្នាជក់ប៉ុណ្ណោះ មិនបានជួញដូរគ្រឿងញៀនទេ។ឯថ្នាំញៀនផ្សេងទៀត មិនមែនជារបស់ខ្លួនទេ គឺសមត្ថកិច្ចយកមកដាក់ទំលាក់កំហុសលើខ្លួនតែប៉ុណ្ណោះ។ខ្លួនមានមុខរបរលក់ទិញកុំព្យូទ័រយកមកជួសជុលដើម្បីយកទៅលក់នៅវៀតណាម។មានឈ្មោះអាម៉ាប់បានយកកាបូប១មកផ្ញើរនៅក្នុងផ្ទះរបស់ខ្លួន។ខ្លួនមិនស្គាល់ឈ្មោះអ្នកលក់ថ្នាំញៀននោះទេ។ឃាយហាយជាអ្នកដាំបាយឲ្យខ្លួន។ខ្លួនទទួលស្គាល់តែថ្នាំហេរ៉ូអ៊ីនទំងន់ប្រហែល១០ជី ជាម្សៅពណ៌ស មានតំលៃប្រហែល៧០០$ជាងប៉ុណ្ណោះសំរាប់ជក់ជាមួយមិត្តភ័ក្រ្ត ខ្លួនមានលក់ដូរថ្នាំយកចំណេញទេ។សំណូមពរសុំបន្ធូរបន្ថយទោសដល់ខ្លួនឲ្យបានទាបផង។

តំណាងមហាអយ្យការសន្និដ្ឋានថា៖ជនជាប់ចោទបានឆ្លើយខុសពីការពិត ជនជាប់

ចោទមានមុខរបរជួសជុលកុំព្យូទ័រនេះសំរាប់បិទបាំងបទល្មើសជួញដូរគ្រឿងញៀន។ ភស្តុតាងទាំងអស់គាំទ្របទចោទ មានធាតុផ្សំគ្រប់គ្រាន់ទៀត ។អង្គហេតុ និង សេចក្តីសំរេចរបស់សាលាដំបូងមានលក្ខណៈត្រឹមត្រូវហើយ សុំតំកល់សាលក្រមព្រហ្មទណ្ឌលេខ៧២ក្រ២/០៩-៦-២០០៩របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការដដែល។

មេធាវី [redacted] ម៉ាច សន្និដ្ឋានថា៖ខ្លួនជាមេធាវីការពារឲ្យឈ្មោះ [redacted]សារុធ។កូនក្តីខ្លួនបានទទួលស្គាល់តែថ្នាំហេរ៉ូអ៊ីនទំងន់ប្រហែល១០ជី ជាម្សៅពណ៌ស មានតំលៃប្រហែល ៧០០$ជាងប៉ុណ្ណោះសំរាប់ជក់ជាមួយមិត្តភ័ក្រ្ត ខ្លួនមានលក់ដូរថ្នាំយកចំណេញទេ។ ឯគ្រឿងញៀនផ្សេងទៀតកូនក្តីខ្លួនមិនទទួលស្គាល់ទេ។សំណូមពរសុំបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនឲ្យបានទាបផង។

## សភាព្រហ្មទណ្ឌ យល់ឃើញថា

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២២-៦-២០០៩ និង បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៥-៨-២០១១ របស់ជនជាប់ចោទឈ្មោ[redacted] សារុធ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ៧២ក្រ២/០៩-៦-២០០៩ និង លេខ៧៧ក្រ១ណចុះថ្ងៃទី០៩-៨-២០១១របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា៣៨២នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ សភាព្រហ្មទណ្ឌអាចទទួលជំនុំជំរះបាន។

២-ពាក្យសុំបញ្ចូលសំណុំរឿងចុះថ្ងៃទី០៣-០១-២០១២របស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted]សារុធ ធ្វើឡើងត្រឹមត្រូវតាមច្បាប់ គប្បីពិចារណា។

៣-តាមចំលើយរបស់ជនជាប់ចោទឈ្មោះ [redacted] សារុធបានឆ្លើយសារភាពថា ថ្នាំញៀនប្រភេទម្សៅហេរ៉ូអ៊ីន ទំងន់៣៩,៩១ក្រាម ពិតជារបស់ខ្លួនពិតប្រាកដមែន។

៤-ជនជាប់ចោទឈ្មោ[redacted] សារុធ បានឆ្លើយទទួលស្គាល់ថា ពេលខ្លួនជាប់ក្នុងពន្ធនាគារ ខ្លួនតែងតែជក់ថ្នាំញៀននៅពេលយប់ជារៀងរាល់ថ្ងៃក្នុងបន្ទប់ ហើយថ្នាំញៀននោះឈ្មោះយាយហាយបានយកមកឲ្យ ដោយលាក់ក្នុងនំប៉័ង ត្រីប្រលាក់ កញ្ចប់បារី ឬផ្ទាល់ដៃនៅពេលគេមិនចាប់អារម្មណ៍។

៥-រឿងក្តីនេះជនជាប់ចោទបានឆ្លើយសារភាពនូវអំពើប្រព្រឹត្តរបស់ខ្លួន ហើយ សាលាដំបូងបានលើកយកសំអាងហេតុមកបញ្ជាក់មានលក្ខណៈគ្រប់គ្រាន់ហើយ ហេតុនេះសភាព្រហ្មទណ្ឌឯកភាពតាមសំអាងហេតុនេះ។

៦-មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោ[redacted]សារុធ ហៅ ធី ពីបទជួញដូរគ្រឿងញៀន ប្រព្រឹត្តនៅសង្កាត់ផ្សារថ្មីទី១ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣-១២-២០០៨ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៣ថ្មី កថាខណ្ឌទី៣ ចំណុច«គ»និង«ជ» នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

និង ពីបទប្រើប្រាស់គ្រឿងញៀនបណ្តាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ប្រព្រឹត្តនៅ

ចំណុចពន្ធនាគារ(PJ)អាគារAក្នុងបន្ទប់លេខ១ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨-១០-២០១០បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៣ថ្មី កថាខណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៧-សាលក្រមព្រហ្មទណ្ឌលេខ៧២ក្រ២/០៩-៦-២០០៩ និង សាលក្រមព្រហ្មទណ្ឌលេខ៧៧ក្រ១ណ/១៩-៨-២០១១របស់សាលាដំបូងរាជធានីភ្នំពេញសំរេចសេចក្តីមានលក្ខណៈត្រឹមត្រូវហើយ គួរតំកល់ទុកជាបានការ តែគប្បីសំរេចបញ្ចូលសំណុំរឿងទាំង២នេះ និង ស្រូបបញ្ចូលសាលក្រមព្រហ្មទណ្ឌដែលមានឈ្មោះ [redacted] សារុធ ហៅ ជី ពីលេខ៧៧ក្រ១ណ/១៩-៨-២០១១ទៅក្នុងសាលក្រមព្រហ្មទណ្ឌលេខ៧២ក្រ២/០៩-៦-២០០៩របស់សាលាដំបូងរាជធានីភ្នំពេញ ដោយផ្តន្ទាទោសសរុបចំនួន១៤ឆ្នាំ(ដប់បួនឆ្នាំ) និងពិន័យជាប្រាក់ចំនួន២០.០០០.០០០៛(ម្ភៃលានរៀល)។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២២-៦-២០០៩ និង បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៥-៨-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] សារុធទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-បញ្ចូលសំណុំរឿងព្រហ្មទណ្ឌលេខ៥៣២ចុះថ្ងៃទី០១-៩-២០០៩ទៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ៩៩០ចុះថ្ងៃទី០២-១១-២០១១របស់សាលាឧទ្ធរណ៍។

៣-តំកល់សាលក្រមព្រហ្មទណ្ឌលេខ៧២ក្រ២/០៩-៦-២០០៩ និង សាលក្រមព្រហ្មទណ្ឌលេខ៧៧ក្រ១ណ/១៩-៨-២០១១របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការ។

៤-ស្រូបបញ្ចូលទណ្ឌកម្មលើឈ្មោះ [redacted] សារុធ ហៅ ជី ពីសាលក្រមព្រហ្មទណ្ឌលេខ៧៧ក្រ១ណ/១៩-៨-២០១១ ទៅក្នុងសាលក្រមព្រហ្មទណ្ឌលេខ៧២ក្រ២/០៩-៦-២០០៩របស់សាលាដំបូងរាជធានីភ្នំពេញ ទោសត្រូវអនុវត្តសរុបចំនួន១៤ឆ្នាំ(ដប់បួនឆ្នាំ) និង ពិន័យជាប្រាក់ចំនួន២០.០០០.០០០៛(ម្ភៃលានរៀល)។

៥-បន្តការឃុំខ្លួនជនជាប់ចោទតាមច្បាប់។

៦-សាលដីកានេះ ប្រកាសជាសាធារណៈនៅថ្ងៃទី០៨-០១-២០១៤ ចំពោះមុខមេធាវី និង ជនជាប់ចោទ ។

បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់។

**សេចក្តនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និង កងកំលាំងប្រដាប់អាវុធគ្រប់ដំណែងជួយសហការអនុវត្តសាលដីកានេះឲ្យបានសំរេច បើមានសំណូមត្រូវគ្រប់តាមច្បាប់.**

**ក្រឡាបញ្ជី** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជំរះ**